ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង៖ ១៨៨/១១-សាន់វែល ស៊ូ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត៖ **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ៖ **អាំង អេងថុង**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន សាន់ វែល ស៊ូ**

អាសយដ្ឋាន ៖ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨៧១ ២៥២ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក Jonhson Chong | Assistant of Director |
| ២- លោក Alex Yu | Assistant of Director |
| ៣- កញ្ញា គុំ វណ្ណារី | រដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពកម្មករនិយោជិត**

- **សហជីពកម្មករនិយោជិតនៃរោងចក្រ សាន់វែលស៊ូ**
- **សហជីពស្មារតីកម្មកររោងចក្រ សាន់វែលស៊ូ**
- **សហជីពឥន្ទ្រៈកម្មករនិយោជិតនៃរោងចក្រ សាន់វែលស៊ូ**

អាសយដ្ឋាន ៖ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩២ ៤៧៤ ១៨៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតៈ

| | |
|---|---|
| ១- លោក វ៉ា វិទ្ធី | មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត |
| ២- លោក ម៉ៃ ស៊ីម៉ា | មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត |
| ៣- លោក សំ វិចិត្រ | ប្រធានសហជីពកម្មករនិយោជិតនៃរោងចក្រ សាន់វ៉ែលស៊ូ |
| ៤- លោក ទូន ភារម្យ | អនុប្រធានសហជីពស្មារតីកម្មករប្រចាំរោងចក្រ សាន់វ៉ែលស៊ូ |
| ៥- លោក ទូច ពិសី | លេខាធិការសហជីពឆន្ទៈកម្មករនិយោជិតប្រចាំរោងចក្រ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

សមាជិកសហជីពកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យសមាជិករបស់ខ្លួនពាក់កាតសហជីពចូលក្នុងរោងចក្រ។ ដោយឡែកភាគីនិយោជិកបញ្ជាក់ថា ក្រុមហ៊ុនមិនអនុញ្ញាតឱ្យសមាជិកសហជីពពាក់កាតរបស់សហជីពចូលក្នុងរោងចក្រឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៤៥៨ កប/អក/វក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យតន្ត្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ"

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ (វេលាម៉ោង ២ រសៀល) ។

THE ARBITRATION COUNCIL

**បញ្ហានៃនីតិវិធីៈ**

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារ បានទទួកពាក្យបណ្តឹងរបស់សហជីពកម្មករនិយោជិត ប្រចាំរោងចក្រ សាន់វើល ស៊ូ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ០៧ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ១៤៥៨ កប/អក/វក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២ វេលាម៉ោង ២ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមានក្នុងសវនាការតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការផ្សះផ្សា និងបានព្យាយាមសួររកនូវព័ត៌មានផ្សេងៗបន្ថែមទៀត ដែលទាក់ទងទៅនឹងមិនសះជាចំនួនសរុប ០១ ចំណុចនេះ ប៉ុន្តែ មិនបានទទួលលទ្ធផលសះជាឡើយ។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្តីសម្រេចនេះជាសេចក្តីសម្រេច ដែលជាប់កាតព្វកិច្ច តាមរយៈអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។ ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីប្រយោជន៍ នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការអនុវត្តសេចក្តីសម្រេចដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។

គូភាគីបានព្រមព្រៀងពន្យាថ្ងៃចេញសេចក្តីបង្គាប់ពីថ្ងៃទី២៥ ទៅដល់ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២។

ក្នុងសំណុំរឿងនេះ ភាគីទាំងពីរបានជ្រើសរើសយកសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីប្រយោជន៍។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោមៈ

THE ARBITRATION COUNCIL

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន សាន់វែលស៊ូ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ។

២- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន សាន់វែលស៊ូ បានចុះបញ្ជិកាលេខ ១៦ កប/អក/អធក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩ ។

៣- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន សាន់វែល ស៊ូ ជូនលោក Johnson Chong ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មករនិយោជិត សាន់វែល ស៊ូ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ ។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពស្មារតីកម្មកររោងចក្រ សាន់វែល ស៊ូ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១

៣- លិខិតស្នើសុំរបស់ថ្នាក់ដឹកនាំសហជីព និងជាកម្មករ កម្មការិនីនៃរោងចក្រ សាន់វែល ស៊ូ គោរពជូន លោក លី វ៉េង ប្រធានសហព័ន្ធសហជីពកម្មករនិយោជិត ស្តីពីការស្នើសុំជួយដោះស្រាយនូវល័ក្ខខ័ណ្ឌការងារជាមួយរោងចក្រ សាន់វែលស៊ូ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១១ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន សាន់វែលស៊ូ លេខ ១៤៥៨ កប/អក/វក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន សាន់វែលស៊ូ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០១០ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០១១ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២ ។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម

- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន សាន់ វ៉េល ស៊ូ បានចាប់ដំណើរការនៅ ខែតុលា ឆ្នាំ២០០៧។ ក្រុមហ៊ុននេះ ជាប្រភេទក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់ ដែលមានជួលកម្មករនិយោជិតប្រហែលចំនួន ១៣០០ នាក់។
- សហជីពដែលជាដើមបណ្តឹង នៅក្នុងសំណុំរឿងនេះ មានចំនួន ៣ គឺ (១) សហជីពកម្មករនិយោជិត (២)សហជីពស្មារតីកម្មករ និង (៣) សហជីពឆន្ទៈកម្មករ។ សហជីពទាំង ៣ នេះ ស្ថិតក្រោមសហព័ន្ធតែមួយគឺ សហព័ន្ធសហជីពកម្មករនិយោជិត។ សហជីពទាំង ៣ មានសមាជិកសរុប ប្រហែល ៧២១ នាក់។ សហជីពកម្មករនិយោជិតប្រចាំក្រុមហ៊ុន សាន់វ៉េលស៊ូ ទទួលបានវិញ្ញាបនប័ត្រចុះបញ្ជិកានៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១។ សហជីពស្មារតីកម្មករប្រចាំក្រុមហ៊ុន សាន់វ៉េលស៊ូ ទទួលបានវិញ្ញាបនប័ត្រចុះបញ្ជិកានៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១។ ដោយឡែក សហជីពឆន្ទៈកម្មករ មិនបានផ្ញើវិញ្ញាបនប័ត្រចុះបញ្ជិការបស់ខ្លួនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

ចំណុចវិវាទ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកអនុញ្ញាតឱ្យសមាជិករបស់ខ្លួនពាក់កាតសហជីពចូលរោងចក្រ

- ការអនុវត្តនៅក្នុងក្រុមហ៊ុននេះ គឺនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតពាក់កាតរបស់ក្រុមហ៊ុនប៉ុណ្ណោះ។
- ភាគីកម្មករនិយោជិត បញ្ជាក់ថា មូលហេតុនៃការទាមទារនេះគឺ (១)សម្រាប់សំគាល់អត្តសញ្ញាណសហជីពរបស់ខ្លួន (២) សហជីពងាយស្រួលអន្តរាគមន៍នៅពេលដែលមានកម្មករនិយោជិតណាម្នាក់ មានគ្រោះថ្នាក់ការងារ និងមានបញ្ហានានា នៅពេលធ្វើដំណើរពីលំនៅស្ថាន ទៅកន្លែងធ្វើការ ឬ វិលត្រឡប់មកផ្ទះវិញ។
- ភាគីកម្មករនិយោជិត បានលើកបន្ថែមទៀតថា កម្មករនិយោជិតដែលជាសមាជិកសហជីពសប្បាយចិត្តនៅពេលដែលពួកគាត់បានពាក់កាតសហជីពចូលមកក្នុងរោងចក្រ ហើយការពាក់កាតនេះគឺ ដាក់នៅពីក្រោយកាតរបស់ក្រុមហ៊ុន។ ការពាក់កាតនេះ គឺមិនមាននាំបញ្ហាអ្វីដល់ក្រុមហ៊ុនឡើយ ព្រោះកម្មករនិយោជិតពាក់តែកាតសហជីពដែលខ្លួនចូលជាសមាជិកប៉ុណ្ណោះ។
- ភាគីនិយោជក បានលើកឡើងថា និយោជកមិនអាចអនុញ្ញាតទេ ដោយសារ (១)ក្រុមហ៊ុនមានសហជីពច្រើន (២) បើនិយោជកអនុញ្ញាតឱ្យមានការពាក់កាតចូលគ្រប់គ្នានោះក្រុមហ៊ុននឹងមានភាពរញ៉េរញ៉ៃជាក់ជាមិនខាន (៣) មិនមានច្បាប់ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនបានចែងអំពីការពាក់កាតសហជីពទេ។
- ភាគីកម្មករនិយោជិត បានអះអាងថា ចាប់តាំងពីបង្កើតសហជីពកម្មករនិយោជិតដំបូង គឺកម្មករនិយោជិតដែលជាសមាជិកសហជីពបានពាក់កាតសហជីពជាធម្មតាទេ ហើយមិនដែលមានបញ្ហាអ្វីជាមួយក្រុមហ៊ុនឡើយ។ ប៉ុន្តែ ក្នុងអំឡុងខែមិថុនា ឬ ខែកក្កដា ឆ្នាំ២០១១ សហជីពមានបញ្ហាជាមួយផ្នែករដ្ឋបាល។ តាំងពីពេលនោះមក គឺនិយោជកមិនអនុញ្ញាតឱ្យពាក់កាតសហជីពទេ។

- ភាគីនិយោជកបដិសេធថា កាលពីដើមមក គឺក្រុមហ៊ុនមិនដែលអនុញ្ញាតឱ្យកម្មករនិយោជិតពាក់កាតសហជីពចូលក្នុងក្រុមហ៊ុនទេ។ ធ្លាប់មានករណីខ្លះ កម្មករនិយោជិតបានពាក់កាតសហជីពចូលទៅក្នុងក្រុមហ៊ុន តែពេលដែលរដ្ឋបាលឃើញ គឺតែងតែហៅកម្មករនិយោជិតណាដែលបានពាក់កាតសហជីពនោះមកប្រាប់ និងហាមឃាត់ពួកគាត់ឈប់ពាក់កាតទៀត។ ភាគីកម្មករនិយោជិតមិនជំទាស់ទៅនឹងការលើកឡើងនេះទេ។

## ហេតុផលនៃសេចក្តីសម្រេចៈ

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើចំណុចវិវាទនេះ ជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "វិវាទអំពីសិទ្ធិ *គឺជាវិវាទទាក់ទងនឹងសិទ្ធិដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញាមួយណាមួយចែងពីការទាមទារនោះ*"។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *០៥/១១-អ៊ឹម វ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ ១៧/១១-ហ្គូល កាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៤/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី៤)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ។

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ចំណុចវិវាទទី១ ជាវិវាទអំពីសិទ្ធិ ព្រោះវិវាទនេះទាក់ទងនឹងសិទ្ធិចាត់ចែងរបស់និយោជក ដែលមានចែងនៅក្នុងមាត្រា ២ នៃច្បាប់ស្តីពីការងារ។

**ចំណុចវិវាទ១ៈ កម្មករនិយោជិតទាមទារឱ្យនិយោជកអនុញ្ញាតឱ្យសមាជិករបស់ខ្លួនពាក់កាតសហជីពចូលរោងចក្រ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា ដូចខាងក្រោមថា ៖

កថាខណ្ឌទី ២ នៃមាត្រា ២ នៃច្បាប់ស្តីពីការងារចែងថា *"សហគ្រាសនីមួយៗអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះមានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក ។"*

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា២ នៃច្បាប់ស្តីពីការងារនេះ មានន័យថា ភាគីនិយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ដរាបណាការនោះ ធ្វើទៅសមហេតុសមផល (សូមមើលសេចក្តីបង្គាប់លេខ លេខ *១៧/០៧-ឆាម ចិចថាយ ហេតុផលនៃចំណុចវិវាទទី៣ លេខ១១៦ /០៧-ហ្គេស សាន់ ហេតុផលចំណុចវិវាទទី ២)* ។

នៅក្នុងករណីនេះ និយោជកអនុញ្ញាតឱ្យកម្មករនិយោជិតពាក់តែកាតរបស់ក្រុមហ៊ុន នៅពេលចេញចូលក្រុមហ៊ុន ហើយមិនអនុញ្ញាតឱ្យកម្មករនិយោជិតពាក់កាតសហជីពចូលបរិវេណក្រុមហ៊ុនឡើយ ដោយសារការពាក់កាតនេះ នឹងបង្កឱ្យមានភាពរញ៉េរញ៉ៃនៅក្នុងក្រុមហ៊ុន ព្រោះថា កម្មករនិយោជិតខ្លះគាត់ចូលជាសមាជិកសហជីពលើសពីមួយ ដូច្នេះបើកនិយោជកអនុញ្ញាតឱ្យកម្មករពាក់កាតសហជីពណាមួយនោះ សហជីពផ្សេងទៀតនឹងទាមទារ

ឱ្យសមាជិករបស់ខ្លួនពាក់កាតសំគាល់សមាជិកសហជីពរបស់ខ្លួនដែរ។ ភាគីកម្មករនិយោជិតបានលើកថា មូលហេតុនៃការទាមទារនេះគឺ (១) សម្រាប់សំគាល់អត្តសញ្ញាណសមាជិកសហជីពរបស់ខ្លួន (២) កម្មករនិយោជិតងាយស្រួលទំនាក់ទំនងទៅសហជីព ឬសហព័ន្ធ នៅពេលដែលមានកម្មករនិយោជិតណាម្នាក់ មានគ្រោះថ្នាក់ការងារ និងមានបញ្ហានានា នៅពេលធ្វើដំណើរពីលំនៅស្ថានទៅកន្លែងធ្វើការ ឬ វិលត្រឡប់មកផ្ទះវិញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការហាមឃាត់កម្មករនិយោជិតពាក់កាតសហជីពចូលបរិវេណក្រុមហ៊ុន គឺជាសិទ្ធិចាត់ចែងរបស់និយោជក ហើយនិយោជកអនុវត្តសិទ្ធិនេះ គឺមានលក្ខណៈសមហេតុសមផលពីព្រោះកាតសម្គាល់សមាជិកសហជីពមិនមែនជាប័ណ្ណសំគាល់របស់ក្រុមហ៊ុន និងមិនមានពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិតនោះទេ។ ហេតុនេះ និយោជកមានសិទ្ធិក្នុងការកំណត់ថា កម្មករនិយោជិតពាក់តែកាតសម្គាល់កម្មករនិយោជិតរបស់ក្រុមហ៊ុនអាច នៅក្នុងម៉ោងការងារ និងមិនអាចពាក់កាតសម្គាល់ផ្សេងទៀតជាមួយនឹងកាតក្រុមហ៊ុនបានទេ។

ម្យ៉ាងវិញទៀត ភាគីកម្មករនិយោជិតមិនបានលើកអំពីសិទ្ធិរបស់កម្មករនិយោជិតដែលបានកំណត់ក្នុងបញ្ញត្តិច្បាប់ណាមួយ ឬក៏កិច្ចព្រមព្រៀងណាមួយនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតពាក់កាតសហជីពនោះ គឺមិនមានមូលដ្ឋានគតិយុត្តត្រឹមត្រូវទេ។

ហេតុដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតពាក់កាតសហជីពនៅក្នុងក្រុមហ៊ុន។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

**១-សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ**

**ចំណុចវិវាទ៖** បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតពាក់កាតសហជីពនៅក្នុងក្រុមហ៊ុន។

**ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ**

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាមហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០។*

២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖ គ្មាន

ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជកៈ

ឈ្មោះ ៖ **អ៊ុង សុទ្ធី**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិតៈ

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា:----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាលៈ

ឈ្មោះ ៖ **អ៊ាំង អេងថុង**

ហត្ថលេខា: ----------------------------------------